# ធនធានសម្រាប់ចំណាត់ការផ្លូវច្បាប់ដែលដាក់លើកម្មវិធីថែទាំកុមារសម្រាប់អ្នកផ្ដល់សេវា



សំណួរ៖

## តើអាជ្ញាបណ្ណថែទាំកុមារ DCYF គឺជាអ្វី?

ចម្លើយ៖

Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) ផ្ដល់អាជ្ញាបណ្ណអំពីកម្មវិធីថែទាំកុមារ និងកម្មវិធីអប់រំកុមារតូចៗចំនួន 6,800 និងទីតាំងសម្រាប់កុមារដល់វ័យសិក្សានៅរដ្ឋ Washington។ អ្នកផ្ដល់សេវាថែទាំកុមារ និងសេវាអប់រំកុមារតូចៗដែលមានអាជ្ញាបណ្ណអនុវត្តតាមស្តង់ដារគុណភាពមូលដ្ឋានដែលកំណត់ដោយ Washington Administrative Code (ច្បាប់រដ្ឋបាល Washington, WAC) ដើម្បីធានាថាកុមារនៅក្នុងកន្លែងថែទាំដែលមានអាជ្ញាបណ្ណស្ថិតក្នុងបរិយាកាសមានសុវត្ថិភាព សុខភាព និងមានការទំនុកបម្រុង។

សំណួរ៖

## តើការព្យួរអាជ្ញាបណ្ណជាបណ្ដោះអាសន្នគឺជាអ្វី?

ចម្លើយ៖

វាគឺជាចំណាត់ការបណ្ដោះអាសន្នដែល DCYF ប្រើដើម្បីរក្សាសុវត្ថិភាពកុមារ។ កម្មវិធីថែទាំកុមារមិនអាចដំណើរការបានទេក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ។ “ព្យួរ” នៅពេលប្រើសំដៅលើស្ថានភាពអាជ្ញាបណ្ណរបស់អ្នកផ្ដល់សេវា មានន័យថាជាចំណាត់ការអនុវត្តច្បាប់ដោយទីភ្នាក់ងារដើម្បីបញ្ឈប់អាជ្ញាបណ្ណជាបណ្ដោះអាសន្ន ដើម្បីការពារសុខភាព សុវត្ថិភាព ឬសុខុមាលភាពរបស់កុមារដែលបានចុះឈ្មោះ ឬសាធារណជន។ (WAC 110-300-0443)
**https://app.leg.wa.gov/WAC/default.aspx?cite=110-300-0443**

សំណួរ៖

## តើនឹងមានអ្វីកើតឡើងនៅពេលដែលអាជ្ញាបណ្ណត្រូវបានព្យួរ?

ចម្លើយ៖

នៅពេលដែលមណ្ឌលថែទាំកុមារត្រូវបានព្យួរអាជ្ញាបណ្ណជាបណ្ដោះអាសន្ន DCYF ជូនដំណឹងដល់អ្នកទទួលអាជ្ញាបណ្ណជាលាយលក្ខណ៍អក្សរ ហើយមណ្ឌល និងប្រតិបត្តិការរបស់ខ្លួនត្រូវតែបិទជាបន្ទាន់។

ប្រសិនបើអ្នកទទួលអាជ្ញាបណ្ណមិនយល់ស្របនឹងការព្យួរអាជ្ញាបណ្ណនេះទេ ពួកគេអាចប្ដឹងឧទ្ធរណ៍ និងបង្ហាញខ្លួននៅចំពោះមុខ Administrative Law Judge (ចៅក្រមច្បាប់រដ្ឋបាល,ALJ) ដើម្បីស្នើសុំ "ការផ្អាក"។ ការផ្អាកអនុញ្ញាតឱ្យមណ្ឌលនេះនៅតែបើករហូតដល់សវនាការត្រូវបានបើក។ ALJ ស្ដាប់អង្គហេតុនៃសំណុំរឿង និងកំណត់សេចក្ដីសម្រេចដែលជាជំហានចុងក្រោយក្នុងដំណើរការបណ្ដឹងឧទ្ធរណ៍។

សំណួរ៖

## តើការដកហូតអាជ្ញាបណ្ណគឺជាអ្វី?

ចម្លើយ៖

ការដកហូតអាជ្ញាបណ្ណគឺជាចំណាត់ការផ្លូវច្បាប់ដែលបិទជាផ្លូវការ និងជាអចិន្ត្រៃយ៍នូវអាជ្ញាបណ្ណថែទាំកុមារ ដែលមានន័យថា មណ្ឌលថែទាំកុមារមិនអាចបើកឡើងវិញបានទេ។

ច្បាប់រដ្ឋ (RCW 43.215) អនុញ្ញាតឱ្យ DCYF ដកហូតអាជ្ញាបណ្ណ នៅពេលដែលអ្នកផ្ដល់សេវាដែលមានអាជ្ញាបណ្ណបង្ហាញការមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិ។ ការដកហូតអាជ្ញាបណ្ណរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះការរំលោភបំពានម្ដងហើយម្ដងទៀតលើច្បាប់ស្ដីពីការចេញអាជ្ញាបណ្ណថែទាំកុមារប៉ុណ្ណោះទេ។ ការដកហូតអាជ្ញាបណ្ណនេះធ្វើឡើងនៅពេលគ្មានចំណាត់ការផ្សេងទៀតនឹងដោះស្រាយកង្វល់បាន។

សំណួរ៖

## តើនឹងមានអ្វីកើតឡើងនៅពេលដែលអាជ្ញាបណ្ណត្រូវបានដកហូត?

ចម្លើយ៖

អ្នកទទួលអាជ្ញាបណ្ណទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរ នៅពេលដែលអាជ្ញាបណ្ណរបស់ពួកគេត្រូវបានដកហូត។ ការជូនដំណឹងនេះរួមមានហេតុផលសម្រាប់ការសម្រេចចិត្តរបស់ DCYF និងការពន្យល់អំពីសិទ្ធិទទួលបាននីតិវិធីយុត្តិធម៌របស់អ្នកទទួលអាជ្ញាបណ្ណ។

ជាការឆ្លើយតបទៅនឹងការជូនដំណឹងនេះ អ្នកទទួលអាជ្ញាបណ្ណអាចធ្វើកិច្ចការមួយក្នុងចំណោមកិច្ចការពីរយ៉ាង៖

a. ប្ដឹងឧទ្ធរណ៍ជំទាស់នឹងចំណាត់ការនេះដោយដាក់សំណើក្នុងរយៈពេល 28 ថ្ងៃទៅ Office of Administrative Hearings (ការិយាល័យសវនាការរដ្ឋបាល, OAH) របស់រដ្ឋ និងការិយាល័យចេញអាជ្ញាបណ្ណថែទាំកុមារ DCYF ក្នុងមូលដ្ឋាន ឬ
b. ទទួលយកការសម្រេចចិត្តរបស់ DCYF និងបិទមណ្ឌលនេះក្នុងរយៈពេល 28 ថ្ងៃបន្ទាប់ពីទទួលបានការជូនដំណឹង។



**សំណួរ៖**

## តើអ្វីទៅជាការផាកពិន័យរដ្ឋប្បវេណី?

**ចម្លើយ៖**

ការផាកពិន័យរដ្ឋប្បវេណី ឬការផាកពិន័យជាប្រាក់គឺជាចំណាត់ការអនុវត្តច្បាប់ដែលធ្វើឡើងដោយទីភ្នាក់ងារ។ នេះអាចជំនួសកិច្ចព្រមព្រៀងអនុលោមភាពនៃការចេញអាជ្ញាបណ្ណដល់មណ្ឌល (FLCA) ឬអាជ្ញាបណ្ណសាកល្បង។ ឧទាហរណ៍ ប្រសិនបើអ្នកផ្តល់សេវាអប់រំកុមារតូចៗបដិសេធ FLCA ឬអាជ្ញាបណ្ណសាកល្បង នោះអាចនឹងមានការដាក់ការពិន័យរដ្ឋប្បវេណី។ ការផាកពិន័យរដ្ឋប្បវេណីគឺជាលទ្ធផលនៃ ប៉ុន្តែមិនកំណត់ត្រឹមចំពោះការរំលោភបំពានម្តងហើយម្តងទៀតលើច្បាប់ស្តីពីការចេញអាជ្ញាបណ្ណថែទាំកុមារប៉ុណ្ណោះទេ។ ការផាកពិន័យរដ្ឋប្បវេណីធ្វើឡើងនៅពេលគ្មានចំណាត់ការផ្សេងទៀតនឹងដោះស្រាយកង្វល់បាន។

**សំណួរ៖**

## តើនឹងមានអ្វីកើតឡើងនៅពេលដាក់ការពិន័យរដ្ឋប្បវេណី?

**ចម្លើយ៖**

អ្នកទទួលអាជ្ញាបណ្ណទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរ នៅពេលដែលការដាក់ពិន័យរដ្ឋប្បវេណីធ្វើឡើង។ ការជូនដំណឹងនេះនឹងរួមបញ្ចូលចំនួនទឹកប្រាក់ផាកពិន័យរដ្ឋប្បវេណី នៅពេលដែលការផាកពិន័យរដ្ឋប្បវេណីត្រូវតែបង់ ហេតុផលសម្រាប់ការសម្រេចចិត្តរបស់ DCYF និងការពន្យល់អំពីសិទ្ធិទទួលបាននីតិវិធីយុត្តិធម៌របស់អ្នកទទួលអាជ្ញាបណ្ណ។

ជាការឆ្លើយតបទៅនឹងចំណាត់ការផាកពិន័យរដ្ឋប្បវេណីនេះ អ្នកទទួលអាជ្ញាបណ្ណអាចធ្វើកិច្ចការមួយក្នុងចំណោមកិច្ចការពីរយ៉ាង៖

a. ប្តឹងឧទ្ធរណ៍ជំទាស់នឹងចំណាត់ការដោយដាក់សំណើក្នុងរយៈពេល 28 ថ្ងៃទៅ OAH ឬ

b. ទទួលយកការសម្រេចចិត្តរបស់ DCYF និងបង់ប្រាក់ពិន័យ។ សូមមើលលិខិតពិន័យរដ្ឋប្បវេណីរបស់អ្នកសម្រាប់ព័ត៌មានលម្អិតអំពីការបង់ប្រាក់ពិន័យរបស់អ្នក។

## លទ្ធផលដែលអាចកើតមាន និងនិយមន័យផ្លូវច្បាប់

**បានបញ្ជាក់៖** សេចក្តីសម្រេចរបស់តុលាការដើម្បីធ្វើសុពលកម្មបញ្ជាក់ ឬតម្កល់សាលក្រមរបស់តុលាការជាន់ទាប។

**បានច្រានចោល៖** សេចក្តីសម្រេចរបស់តុលាការក្នុងការបញ្ចប់សំណុំរឿងរបស់តុលាការលើចុងចោទ។ ការច្រានចោលអាចមានហេតុផលជាច្រើន រួមទាំងសំណើទៅវិញទៅមករបស់គូភាគីការដោះស្រាយដោយការផ្សះផ្សា ការខកខានរបស់ភាគីប្តឹងឧទ្ធរណ៍ក្នុងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ ឬសេចក្តីសម្រេចថា តាមផ្លូវច្បាប់ ភាគីប្តឹងឧទ្ធរណ៍មិនអាចសម្រេចបានលទ្ធផលដែលពួកគេបានស្វែងរកតាមរយៈបណ្តឹងឧទ្ធរណ៍នោះទេ។ ការច្រានចោលនៅ OAH ដោយសារហេតុផលណាមួយ ដោយទុករយៈពេល 20 ថ្ងៃឲ្យអ្នកប្តឹងឧទ្ធរណ៍ព្យាយាមដាក់បណ្តឹងឧទ្ធរណ៍ឡើងវិញ។

**នីតិវិធីយុត្តិធម៌៖** ត្រូវបានរួមបញ្ចូលនៅក្នុងវិសោធនកម្មលើកទី 14 នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក វាធានាថារដ្ឋនឹងប្រព្រឹត្តចំពោះបុគ្គលម្នាក់ៗដោយយុត្តិធម៌ជាមូលដ្ឋាន និងការពារសិទ្ធិរបស់បុគ្គលម្នាក់ក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងចំណាត់ការអវិជ្ជមានប្រឆាំងនឹងអាជ្ញាបណ្ណ ឬសេចក្តីសម្រេចដែលបង្កើតឡើងដោយសារការរំលោភបំពាន ឬការធ្វេសប្រហែសលើកុមារ។

**បានដកចេញ៖** ដើម្បីលុបបំបាត់ឥទ្ធិពលនៃចំណាត់ការផ្លូវច្បាប់ដោយមិនដកចេញនូវការដាក់ចំណាត់ការនោះជាផ្លូវការ។ ម្យ៉ាងវិញទៀត ចំណាត់ការនឹងនៅតែជាចំណាត់ការផ្លូវច្បាប់របស់ទីភ្នាក់ងារដដែល ប៉ុន្តែអ្នកផ្តល់សេវាអាចមិនអើពើនឹងចំណាត់ការនេះ បន្ទាប់ពីវាត្រូវបានដកចេញ ទោះបីជាវានៅតែស្ថិតក្នុងកំណត់ត្រារបស់អ្នកផ្តល់សេវាក៏ដោយ។ ការដកចេញត្រូវបានប្រើសម្រាប់ការព្យួរជាបណ្តោះអាសន្ននៅពេលទីភ្នាក់ងារនេះមិនជឿថាមានហានិភ័យដែលអាចកើតមានចំពោះកុមារ ប៉ុន្តែមិនទាន់បានសម្រេចចិត្តថាការព្យួរជាបណ្តោះអាសន្នគួរតែត្រូវបានបោះបង់ចោលទាំងស្រុងនោះទេ។

**ចំណាត់ការអវិជ្ជមាន៖** ដីកាតុលាការ សាលក្រមតុលាការ ឬចំណាត់ការអវិជ្ជមានដែលធ្វើឡើងដោយទីភ្នាក់ងារ នៅក្នុងយុត្តាធិការរដ្ឋ សហព័ន្ធ កុលសម្ព័ន្ធ ឬយុត្តាធិការបរទេសណាមួយ។ វានាំឱ្យមានសេចក្តីសម្រេចប្រឆាំងនឹងអ្នកដាក់ពាក្យ ដែលទាក់ទងដោយសមហេតុផលនឹងលក្ខណៈបុគ្គល ភាពស័ក្តិសម និងសមត្ថភាពក្នុងការថែទាំ ឬមិនមានការត្រួតពិនិត្យចំពោះកុមារនៅក្នុងកន្លែងថែទាំកុមារ។ នេះអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមចំពោះ៖

a. សេចក្តីសម្រេចដែលចេញដោយ ALJ

b. ការកំណត់សម្រេច សេចក្តីសម្រេចចិត្ត ឬសេចក្តីសម្រេចចុងក្រោយដែលធ្វើឡើងដោយទីភ្នាក់ងារបន្ទាប់ពីការស៊ើបអង្កេត

c. ចំណាត់ការអវិជ្ជមានរបស់ទីភ្នាក់ងារ រួមទាំងការបញ្ចប់ ការដកហូត ឬការបដិសេធអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬប្រសិនបើចំណាត់ការអវិជ្ជមានរបស់ទីភ្នាក់ងារដែលមិនទាន់សម្រេច ការប្រគល់វិញដោយស្ម័គ្រចិត្តនៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬកិច្ចសន្យាជំនួសឱ្យចំណាត់ការអវិជ្ជមាន

d. ការដកហូត ការបដិសេធ ឬការរឹតបន្តឹងលើអាជ្ញាបណ្ណវិជ្ជាជីវៈណាមួយ ឬ

e. សេចក្តីសម្រេចចិត្តចុងក្រោយរបស់ក្រុមប្រឹក្សាវិន័យ។

**គ្មានការប្តឹងឧទ្ធរណ៍៖** ប្រសិនបើគ្មានការប្តឹងឧទ្ធរណ៍ទេ វាមានន័យថាចំណាត់ការរបស់ទីភ្នាក់ងារនេះនៅតែជាធរមាន។ លិខិតផ្លូវច្បាប់នៅក្នុងករណីចេញអាជ្ញាបណ្ណជូនដំណឹងដល់អ្នកផ្តល់សេវាថា ប្រសិនបើពួកគេមិនស្វែងរកសវនាការនៅ OAH របស់រដ្ឋនោះទេ ចំណាត់ការនេះនឹងត្រូវបានដាក់ឱ្យចូលជាធរមានក្នុងរយៈពេល 28 ថ្ងៃបន្ទាប់ពីពួកគេត្រូវបានប្រគល់លិខិតនោះ។ ការលើកលែងតែមួយគត់គឺសម្រាប់តែការព្យួរជាបណ្តោះអាសន្ន ដែលមានប្រសិទ្ធភាពភ្លាមៗ។ ប្រសិនបើអ្នកផ្តល់សេវាមិនស្វែងរកសវនាការក្នុងរយៈពេល 28 ថ្ងៃបន្ទាប់ពីការព្យួរជាបណ្តោះអាសន្ននោះទេ ចំណាត់ការនេះគឺសម្រេចជាស្ថាពរ ហើយនៅតែបិទ។

**បាននិរាករ៖** ដើម្បីលុបចោលចំណាត់ការ។ នៅពេលដែលចំណាត់ការផ្លូវច្បាប់ត្រូវបាននិរាករ វាមានន័យថា ចំណាត់ការផ្លូវច្បាប់នឹងលែងមាននៅលើកំណត់ត្រារបស់អ្នកផ្តល់សេវាទៀតហើយ។ ការនិរាករការព្យួរជាបណ្តោះអាសន្នជាញឹកញាប់ធ្វើឡើងបន្ទាប់ពីការដកចេញនូវការព្យួរជាបណ្តោះអាសន្ន នៅពេលដែលទីភ្នាក់ងារមានព័ត៌មានចាំបាច់ទាំងអស់ដើម្បីសម្រេចថាខ្លួននឹងមិនបន្តការព្យួរជាបណ្តោះអាសន្នទៀតទេ។

**ការផ្សះផ្សា៖** កិច្ចព្រមព្រៀងដែលបញ្ចប់វិវាទ ហើយបណ្តាលឱ្យមានការលុបចោលដោយស្ម័គ្រចិត្តនៃបណ្តឹងវិវាទដែលពាក់ព័ន្ធ។

**បានផ្អាក៖** “ការផ្អាក” គឺជាចំណាត់ការដែលធ្វើឡើងដោយតុលាការដើម្បីបញ្ឈប់ឥទ្ធិពលនៃដំណើរការផ្លូវច្បាប់លើចំណាត់ការរបស់ភាគីម្ខាង។ វាត្រូវបានប្រើសម្រាប់ការព្យួរជាបណ្តោះអាសន្ន។ អ្នកផ្តល់សេវាដែលចង់ធ្វើប្រតិបត្តិការនៅពេលប្តឹងឧទ្ធរណ៍ជំទាស់នឹងការព្យួរជាបណ្តោះអាសន្នអាចស្នើសុំ OAH របស់រដ្ឋឱ្យផ្អាកការព្យួរជាបណ្តោះអាសន្នបាន។ ប្រសិនបើការផ្អាកត្រូវបានអនុញ្ញាត អ្នកផ្តល់សេវានឹងអាចដំណើរការក្នុងអំឡុងពេលសវនាការ ដើម្បីសម្រេចថាតើការព្យួរជាបណ្តោះអាសន្នត្រូវបានអនុវត្តត្រឹមត្រូវដែរឬទេ។

**បានតម្កល់៖** ដើម្បីវិនិច្ឆ័យសេចក្តីសម្រេចផ្លូវច្បាប់ថាត្រឹមត្រូវ និងដើម្បីសម្រេចមិនកែប្រែចំណាត់ការផ្លូវច្បាប់។

សម្រាប់ព័ត៌មានអំពីការរៀបចំសម្រាប់សវនាការ DCYF សូមចូលទៅកាន់គេហទំព័រ៖ **https://oah.wa.gov/case-preparation/hearings/department-children-youth-families**

សម្រាប់ព័ត៌មានអំពីច្បាប់ និងវិធាននានាទាក់ទងនឹងការចេញអាជ្ញាបណ្ណថែទាំកុមារ សូមចូលទៅកាន់គេហទំព័រ៖ **www.dcyf.wa.gov/practice/policy-laws-rules**

## មានសំណួរដែរទេ?

សូមទាក់ទងអ្នកផ្តល់អាជ្ញាបណ្ណរបស់អ្នក ឬមន្ត្រីផ្នែកអប់រំកុមារតូចៗ និងមន្ត្រីផ្នែកថែទាំកុមារប្រចាំមូលដ្ឋានរបស់អ្នកតាមគេហទំព័រ
**www.dcyf.wa.gov/find-an-office/el-offices**